# សេចក្ដីអំពាវនាវដល់កូនខ្មែរទាំងអស់
# ដែលមានសិទ្ធិបោះឆ្នោតទៅបោះឆ្នោតទាំងអស់គ្នា

ដោយសេង ភក្តី (សុភ័ណ)

*ខ្ញុំសូមអំពាវនាវដល់បងប្អូនជនរួមជាតិខ្មែរទាំងអស់ សូមមេត្តាទៅបោះឆ្នោត នៅថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០១៣ ទាំងអស់គ្នាកុំបីអាក់ខានឡើយ។*

ការចូលរួមបោះឆ្នោតរបស់អ្នកគឺការចូលរួមធ្វើនយោបាយជីវិតរបស់អ្នក។

## ចុះអ្វីគឺនយោបាយ?

# នយោបាយគឺឆ្នាំងបាយ...

ព្រះពុទ្ធអង្គសំដែងថា សត្វទាំងឡាយរស់នៅបានដោយអាស្រ័យអាហារ។ ដូច្នេះចូរអ្នកទាំងឡាយចូលរួមបោះឆ្នោតដើម្បី ជីវិតធូរធារ ដើម្បីមានការងារធ្វើដែលទទួលបានប្រាក់កំរៃសមរម្យ ដើម្បីការអភិវឌ្ឍន៍សេដ្ឋកិច្ច ប្រកបដោយសមភាពនិងចិរភាព។

# នយោបាយគឺសុខមាលភាពរបស់យើង...

យើងបោះឆ្នោតដើម្បីបានមកនូវសុខភាពផ្លូវកាយ និងសុខភាពផ្លូវចិត្តរបស់យើង។ សុខភាពផ្លូវកាយគឺការមានសេវាកម្មសុខាភិបាលដែលថោកឬមិនគិតថ្លៃ។

សុខភាពផ្លូវចិត្តគឺ ការមានសិទ្ធិសេរីភាពពេញលេញ ក្នុងឋានះយើងជាសមាជិកនៃសង្គមប្រជាធិបតេយ្យ ជាពិសេសគឺយើងមានតុលាការនិងសារពត៌មានដែលមានយុត្តិធម៌និងឯករាជ្យ។

## នយោបាយគឺសិទ្ធិសេរីភាព...

ព្រះពុទ្ធអង្គសង្កត់ធ្ងន់ថាសេរីភាពគឺជាគោលដៅខ្ពស់បំផុតរបស់មនុស្សជាតិ
ដូច្នេះសេរីភាពបានដល់ការអស់ទៅនូវ **ខ្លៅ ឃ្លាន ខ្លាច**
ហើយចាប់ផ្តើមពង្រឹងនីតិរដ្ឋតាមបែបលទ្ធិប្រជាធិបតេយ្យពិតប្រាកដ។

## នយោបាយគឺអធិបតេយ្យភាពជាតិ...

ចំណុចនេះសំខាន់ណាស់ យើងបោះឆ្នោតដើម្បីការពារអធិបតេយ្យជាតិខ្មែរ យើងហើយយើងរាប់អានបរទេសនិងប្រទេសជិតខាង ក្នុងឋានះស្មើភាពគ្នា មិនអាចមាននរណាយកប្រៀបលើនរណាបានទេ។

### សូមកុំភ្លេចទៅបោះឆ្នោតទាំងអស់គ្នាដើម្បីការផ្លាស់ប្តូរ *ដែលនាំមកនូវឆ្នាំងបាយ សុខមាលភាព សេរីភាព និងអធិបតេយ្យភាពពិតប្រាកដ* ។